**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**
លេខ : ០០២ ក្រប្រក/សសរ

# សេចក្តីសម្រេច
# ស្តីពី
# ការតែងតាំងសមាសភាពគណៈកម្មាធិការសវនកម្ម

## ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៩

- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ០៨ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការកែសម្រួលមាត្រា៨ថ្មី នៃអនុក្រឹត្យលេខ៣៤ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៦ ស្តីពីការបង្កើតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៧១ អនក្រ.បក ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១១ ស្តីពីការបំពេញបន្ថែមលើអនុក្រឹត្យលេខ៤១ អនក្រ.បក ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.តត ចុះថ្ងៃទី៦ ខែមករា ឆ្នាំ២០២៦ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៩
- បានឃើញអនុក្រឹត្យលេខ២៤៤ អនក្រ.តត ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦ ស្តីពីការតែងតាំងអគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងការកែសម្រួលសមាសភាពក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ អាណត្តិទី៩
- បានឃើញប្រកាសលេខ០១១/១៨ គ.ម.ក/ប្រ.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- យោងកំណត់ហេតុប្រជុំលើកទី១របស់ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញអាណត្តិទី៩ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦

## សម្រេច

**ប្រការ ១** : ត្រូវបានតែងតាំងសមាសភាពគណៈកម្មាធិការសវនកម្ម ដូចខាងក្រោម ៖

| | | |
|---|---|---|
| ១. **លោក ស្រេង សំឱក** | សមាជិកក្រុមប្រឹក្សាភិបាល អភិបាលឯករាជ្យ | ប្រធាន |
| ២. **ឯកឧត្តម ម៉ី វ៉ាន់** | សមាជិកក្រុមប្រឹក្សាភិបាល តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. **លោក ណាំ ចន្ទ្រី** | សមាជិកក្រុមប្រឹក្សាភិបាល អភិបាលមិនប្រតិបត្តិតំណាងភាគហ៊ុនិកឯកជន | សមាជិក |
| ៤. **ឯកឧត្តម នេត មុន្នី** | មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | សមាជិក |
| ៥. **តំណាងនិយោជិតរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ** | | សមាជិក |

**ប្រការ ២** : គណៈកម្មាធិការសវនកម្មត្រូវបំពេញតួនាទី និងភារកិច្ចដូចខាងក្រោម ៖

- តាមដានដំណើរការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងត្រួតពិនិត្យ និងវាយតម្លៃសុក្រឹត្យភាព និងភាពពេញលេញនៃរបាយការណ៍ហិរញ្ញវត្ថុ ក៏ដូចជារបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
- ត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គភាព
- ជួបប្រជុំជាមួយគណៈគ្រប់គ្រង ដើម្បីពិភាក្សាអំពីរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មប្រចាំត្រីមាស និងប្រចាំឆ្នាំ
- ពិនិត្យ តាមដាន និងវាយតម្លៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដើម្បីធានាថាប្រព័ន្ធទាំងនេះមានប្រសិទ្ធភាពក្នុងការកាត់បន្ថយហានិភ័យ
- ត្រួតពិនិត្យគោលនយោបាយគ្រប់គ្រងហានិភ័យរបស់អង្គភាព រួមទាំងការងារតាមដានប្រសិទ្ធភាពការងាររបស់សវនករ និងគណៈគ្រប់គ្រង
- ពិនិត្យមើលទំហំការងារ និងការបំពេញតួនាទីរបស់សវនកម្មផ្ទៃក្នុង ព្រមទាំងតាមដាននិងវាយតម្លៃប្រសិទ្ធភាពការងាររបស់សវនកម្មផ្ទៃក្នុង
- លើកសំណើជូនក្រុមប្រឹក្សាភិបាលពិនិត្យ-សម្រេចលើការជ្រើសរើសក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យមូលបត្រ ដែលទទួលបានការទទួលស្គាល់ពីនិយ័តករមូលបត្រកម្ពុជា មកធ្វើសវនកម្មហិរញ្ញវត្ថុជូនអង្គភាព ព្រមទាំងត្រួតពិនិត្យអន្តរកម្មការងាររវាងអង្គភាព និងសវនករឯករាជ្យ
- ត្រួតពិនិត្យទៅលើឯករាជ្យភាព គុណវុឌ្ឍិ ទំហំការងារ និងការបំពេញតួនាទីរបស់សវនករឯករាជ្យ ព្រមទាំងទំនាក់ទំនងរវាងអង្គភាព និងសវនករឯករាជ្យ
- ត្រួតពិនិត្យដំណើរការរបស់អង្គភាព និងប្រសិទ្ធភាពនៃប្រព័ន្ធគ្រប់គ្រង ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន
- ប្រជុំយ៉ាងតិចណាស់រៀងរាល់មួយត្រីមាសម្តង។

**ប្រការ ៣** : សេចក្តីសម្រេចលេខ០០៥ ក្រប្រក/សសរ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៥ របស់ក្រុមប្រឹក្សាភិបាលរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការសវនកម្ម និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៤** ៖ សមាជិកក្រុមប្រឹក្សាភិបាល អគ្គនាយក គ្រប់អគ្គនាយករង គ្រប់នាយកដ្ឋាន អង្គភាពចំណុះរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៧កើត ខែ ចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០២៦

**ជ. ក្រុមប្រឹក្សាភិបាល**

**ប្រធាន**

**ឯក សុនចាន់**

**ចម្លងជូន ៖**

- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- និយ័តករមូលបត្រកម្ពុជា
- មន្ត្រីត្រួតពិនិត្យរដ្ឋអមរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- ដូចប្រការ ៤
- ឯកសារ-កាលប្បវត្តិ